ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការកំណត់ ថវិកាសំរាប់កែលំអព្រលានយន្តហោះពោធិចិនតុង

***

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងអនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

## សំរេច

ប្រការ ១ : នាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ត្រូវដកប្រាក់ចំនួន ២០ ភាគរយ នៃប្រាក់ចំណូលសរុប ដែលបាន មកពីពន្ធចុះចតពន្ធព្រលានយន្តហោះ និង ចំណូលផ្សេងៗ ទៀតសំរាប់ធ្វើការកែលំអ និង រៀបចំឡើង វិញ ព្រលានយន្តហោះពោធិចិនតុង ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

****